IHSS
IN-HOME SUPPORTIVE SERVICES
TELEPHONE TIMESHEET SYSTEM



# ការពិនិត្យមើលផ្ទៀងផ្ទាត់តាមអេឡិចត្រូនិច

## ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការនៃកម្មវិធី IHSS

## ការពិនិត្យឡើងវិញនៃប្រវត្តិលើទំព័រកត់ត្រាពេលម៉ោងធ្វើការ របស់អ្នកទទួលជំនួយ

សម្រាប់ជំនួយបន្ថែម សូមទាក់ទងទៅការិយាល័យសេវាកម្មផ្នែកកម្មវិធី IHSS តាមលេខទូរស័ព្ទ (866) 376-7066 នៅពេលម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ ពីម៉ោង 8am ទៅម៉ោង 5pm ។



ប្រព័ន្ធទូរស័ព្ទទំព័រកត់ត្រាពេលម៉ោងធ្វើការ (TTS) នៃកម្មវិធី IHSS ផ្តល់ជូនលក្ខណៈពិសេសលើប្រវត្តិនៃទំព័រកត់ត្រាពេលម៉ោងធ្វើការ សំរាប់ឱ្យអ្នកពិនិត្យឡើងវិញនូវទំព័រកត់ត្រាពេលម៉ោងធ្វើការ ក្នុងរយៈពេលបីខែមុន ដែលអ្នកបានយល់ព្រម ឬ បដិសេធ ។

ដើម្បីចូលទៅដល់ប្រវត្តិនៃទំព័រកត់ត្រាពេលម៉ោងធ្វើការ សំរាប់ TTS សូមចុច **(833) DIAL-EVV ឬលេខ (833) 342-5388 ។** អ្នកនឹងត្រូវបានរំលឹកប្រាប់ឱ្យបញ្ចូលលេខ 7 ខ្ទង់របស់អ្នកទទួលជំនួយ របស់អ្នក និង លេខកូដសម្ងាត់របស់អ្នក ។ វាគឺជាការសំខាន់ដែលអ្នកត្រូវរក្សាទុក លេខកូដសម្ងាត់របស់អ្នកឱ្យមានសុវត្ថិភាព ហើយ មិនត្រូវប្រាប់ឬបង្ហាញឱ្យគេដឹងនូវលេខកូដសម្ងាត់របស់អ្នកឡើយ ។ បន្ទាប់ពីការចូលរបស់អ្នកទទួលជំនួយ បានដោយជោគជ័យ **សូមចុចលេខ 2** ពីម៉ឺនុយដំណើរសកម្មភាពការងារ (Activity Menu) ដើម្បីស្តាប់ទំព័រកត់ត្រាពេលម៉ោងធ្វើការដែលបានយល់ព្រម ឬ បដិសេធពីពេលមុន ។




បើសិនជាអ្នកមិនមានចំណាត់ការដែលបានយល់ព្រម ឬ បដិសេធនៅលើទំព័រកត់ត្រាពេលម៉ោងធ្វើការក្នុងរយៈពេលបី (3) ខែមុនទេ, TTS នឹងនិយាយថា:

**"មិនមានចំណាត់ការយល់ព្រម ឬ បដិសេធលើទំព័រកត់ត្រាពេលម៉ោងធ្វើការ ក្នុងរយៈពេលបីខែមុនទេ ។ បើសិនជាអ្នកគិតថាព័ត៌មាននេះគឺមិនត្រឹមត្រូវ សូមទាក់ទងទៅការិយាល័យខោនធីរបស់អ្នក ។ សូមចុចលេខ 8 ដើម្បីត្រឡប់ទៅម៉ឺនុយដំណើរសកម្មភាពការងារ (Activity Menu) បើមិនដូច្នេះទេ អ្នកអាចដាក់ទូរស័ព្ទចុះនៅពេលណាក៏បាន" ។**

បើសិនជាអ្នកមានចំណាត់ការដែលបានយល់ព្រម ឬ បដិសេធនៅលើទំព័រកត់ត្រាពេលម៉ោងធ្វើការក្នុងរយៈពេលបី (3) ខែមុន, TTS នឹងនិយាយថា:

**"នៅទីនេះគឺជាចំណាត់ការ យល់ព្រមឬបដិសេធ ដែលបានធ្វើឡើង នៅលើទំព័រកត់ត្រាពេលម៉ោងធ្វើការរបស់អ្នកសំរាប់រយៈពេល 3 ខែមុន ។ នៅពេលណាក៏ដោយ ក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញនូវប្រវត្តិលើទំព័រកត់ត្រាពេលម៉ោងធ្វើការ អ្នកអាចចុចលេខ '8' ដើម្បីត្រឡប់ទៅរកម៉ឺនុយដំណើរសកម្មភាពការងារ" ។**

TTS នឹងអានទំព័រកត់ត្រាពេលម៉ោងធ្វើការទាំងអស់នោះ តាមលំដាប់លំដោយ ចាប់ពីទំព័រកត់ត្រាពេលម៉ោងធ្វើការដែលថ្មីៗបំផុត រហូតដល់ទំព័រកត់ត្រាពេលម៉ោងធ្វើការដែលយូរណាស់មកហើយ ។

កត់សំគាល់: < > នឹងត្រូវជាព័ត៌មានដែលទាក់ទងនឹងអ្នកផ្តល់សេវារបស់អ្នក ហើយនឹងទំព័រកត់ត្រាពេលម៉ោងធ្វើការដែលអ្នកបានយល់ព្រម ឬ បដិសេធ ។

"**អ្នក** <បានបដិសេធ ឬ បានយល់ព្រម> **លើ** <អ្នកផ្តល់សេវាផ្ទាល់ខ្លួន, ប្រាក់បង់ឱ្យមុន> <ប្រាក់លើកដំបូង ឬ ប្រាក់បន្ថែម> **លើទំព័រកត់ត្រាពេលម៉ោងធ្វើការ សម្រាប់កម្មវិធី** <IHSS ឬ WPCS> **ដែលបានដាក់ស្នើដោយអ្នកផ្តល់សេវារបស់អ្នក** <ឈ្មោះអ្នកផ្តល់សេវា> **សម្រាប់អំឡុងពេលបើកប្រាក់ខែ ចាប់ផ្តើមនៅ** <កាលបរិច្ឆេទចាប់ផ្តើមនៃអំឡុងពេលបើកប្រាក់ខែ> **និង បញ្ចប់នៅ** <កាលបរិច្ឆេទបញ្ចប់នៃអំឡុងពេលបើកប្រាក់ខែ>" ។

បន្ទាប់ពី TTS អានទំព័រកត់ត្រាពេលម៉ោងធ្វើការដែលមានផ្តល់ជូនទាំងអស់ រួចហើយ, TTS នឹងនិយាយថា:

**"អ្នកមិនមានការពិនិត្យឡើងវិញនៃប្រវត្តិលើទំព័រកត់ត្រាពេលម៉ោងធ្វើការទេ ។ សូមចុចលេខ '8' ដើម្បីត្រឡប់ទៅម៉ឺនុយដំណើរសកម្មភាពការងារ ឬ អ្នកអាចដាក់ទូរស័ព្ទចុះនៅពេលណាក៏បាន" ។**